**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០៥៣ ប្រក

ថ្ងៃ អង្គារ ២រោច ខែចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២១

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មកីឡាទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងប្រកាសលេខ១៤៦ ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្តនិងកីឡាទេសចរណ៍
- យោងប្រកាសលេខ១៥២ ប្រក ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសកម្មភាពកីឡាទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

និវេសនដ្ឋានលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់គុណភាពសេវាកម្មកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ ស្របតាមលក្ខណៈបច្ចេកទេសកីឡា និងធានាសន្តិសុខ សុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

**ប្រការ២ ._**

ប្រកាសនេះ មានគោលដៅកំណត់វិធាន និងយន្តការគ្រប់គ្រងសកម្មភាពអាជីវកម្មកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តរាល់ប្រភេទអាជីវកម្មកីឡាទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ និងដែលមានកំណត់នៅក្នុងប្រកាសអន្តរក្រសួង លេខ១៦០ សហវ.ប្រក ចុះថ្ងៃទី១៧ កុម្ភៈ ឆ្នាំ២០២០ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ រួមមានដូចជា៖ ក្លឹបកម្សាន្តប៊ូលីង ក្លឹបហ្វឹកហាត់វាយកូនគោល ក្លឹបកីឡាវាយកូនគោល កីឡាប្រណាំងឡាន កីឡាបាញ់ព្រួញ និងកាំភ្លើងគ្រាប់មិនពិត កីឡាស្គីលើទឹក កីឡាក្តារបណ្តែត ទូកបណ្តែត កីឡាហែលទឹក កីឡាមុជទឹក បាល់ទះបង្ហោះ រថយន្តខ្សែកាប យន្តហោះ ឬឧទ្ធម្ភាគចក្រជិះកម្សាន្ត។

ប្រកាសនេះ មិនអនុវត្តចំពោះ៖

- ប្រភេទក្លឹបកីឡាទេសចរណ៍ ដែលជាសមាជិករបស់សហព័ន្ធកីឡាជាតិ ដែលរៀបចំឡើងក្នុងគោលបំណងអភិវឌ្ឍ ផ្សព្វផ្សាយ ហ្វឹកហាត់ អប់រំបណ្តុះបណ្តាល និងការប្រកួតក្របខណ្ឌថ្នាក់ជាតិ អន្តរជាតិ ដោយមិនធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ
- ប្រភេទកីឡាទេសចរណ៍លេងកម្សាន្តដែលជាកម្មសិទ្ធឯកជនផ្ទាល់ខ្លួន។

**ប្រការ៤ ._**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មានន័យដូចខាងក្រោម៖

- **បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល
- **ប្រតិបត្តិករទេសចរណ៍** សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីវកម្ម ឬធ្វើអាជីវកម្មសេវាកម្មទេសចរណ៍
- **កីឡាទេសចរណ៍**សំដៅដល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងកីឡារបស់បុគ្គលដែលធ្វើដំណើរទៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់ពួកគេក្នុងគោលបំណងទស្សនា កម្សាន្តសប្បាយចូលរួម លេងកម្សាន្ត ឬប្រកួតប្រជែងក្នុងសកម្មភាពកីឡាទេសចរណ៍។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់អាជីវកម្មកីឡាទេសចរណ៍

**ប្រការ៥ ._**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្នចំពោះអាជីវកម្មកីឡាទេសចរណ៍ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍។

ការធ្វើប្រតិភូកម្មមុខងារផ្តល់អាជ្ញាបណ្ណទេសចរណ៍ ការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃក្នុងការផ្តល់អាជ្ញាបណ្ណកីឡាទេសចរណ៍ ចំពោះអាជីវកម្មកីឡាទេសចរណ៍ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ៦ ._**

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មកីឡាទេសចរណ៍បានដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ដែលផ្តល់ដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**ប្រការ៧. _**

បុគ្គលដែលប្រកបអាជីវកម្មកីឡាទេសចរណ៍ច្រើនប្រភេទនៅលើទីតាំងតែមួយ ប្រភេទអាជីវកម្មនីមួយៗត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។

បុគ្គលដែលប្រកបអាជីវកម្មកីឡាទេសចរណ៍មួយប្រភេទហើយមានសាខាច្រើនកន្លែង សាខានីមួយៗនោះត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។

## ជំពូកទី ៣
## ការកំណត់ប្រភេទ និងទីតាំងអាជីវកម្មកីឡាទេសចរណ៍

**ប្រការ៨ ._**

ប្រភេទអាជីវកម្មកីឡាទេសចរណ៍រួមមាន៖

- ប្រភេទកីឡាទេសចរណ៍ដែលផ្តល់សេវាហ្វឹកហាត់ជំនាញដល់កីឡាករ កីឡាការិនីដែលជួយទ្រទ្រង់ដល់សហព័ន្ធកីឡាជាតិ
- ប្រភេទកីឡាទេសចរណ៍ ដែលផ្តល់សេវាហ្វឹកហាត់ជំនាញដល់កីឡាករ កីឡាការិនីដែលជួយទ្រទ្រង់ដល់សហព័ន្ធកីឡាជាតិ និងធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ
- ប្រភេទកីឡាទេសចរណ៍ ដែលផ្តល់សេវាកម្មបម្រើភ្ញៀវ ក្នុងគោលបំណងធ្វើអាជីវកម្មដើម្បីរកប្រាក់កម្រៃ
- ប្រភេទកីឡាទេសចរណ៍លេងកម្សាន្តដែលជាកម្មសិទ្ធឯកជនផ្ទាល់ខ្លួន។

**ប្រការ៩ ._**

រដ្ឋបាលថ្នាក់ក្រោមជាតិជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំ និងកំណត់ទីតាំងអាជីវកម្មកីឡាទេសចរណ៍ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។



ហត្ថលេខាតូច: [illegible]

ការកំណត់ទីតាំងធ្វើសកម្មភាពរបស់អាជីវកម្មកីឡាទេសចរណ៍ ត្រូវស្ថិតនៅទីតាំងសមស្របតាមប្រភេទអាជីវកម្មកីឡាទេសចរណ៍នីមួយៗ ដោយធានារក្សាប្រពៃណី ទំនៀមទម្លាប់ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងបរិស្ថានឱ្យបានល្អ។

## ជំពូកទី ៤
## វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់អាជីវកម្មកីឡាទេសចរណ៍

**ប្រការ១០ ._**

បុគ្គលដែលប្រកបអាជីវកម្មកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍ខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

**១.ចំពោះអាជីវកម្មកីឡាទេសចរណ៍៖** ក្លឹបកម្សាន្តប៊ូលីង ក្លឹបហ្វឹកហាត់វាយកូនគោល ក្លឹបកីឡាវាយកូនគោល កីឡាប្រណាំងឡាន កីឡាបាញ់ព្រួញ និងកាំភ្លើងគ្រាប់មិនពិត កីឡាស្គីលើទឹក កីឡាក្តារបណ្តែត ទូកបណ្តែត កីឡាហែលទឹក និងកីឡាមុជទឹក។

- **ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍(ថ្មី)ត្រូវបំពេញសំណុំបែបបទនិងលក្ខខណ្ឌដូចខាងក្រោម៖**
  - ក. វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
  - ខ. លិខិតអនុញ្ញាតទីតាំងអាជីវកម្ម (ប្រកបអាជីវកម្មក្នុងទីតាំងដែលអាជ្ញាធរមូលដ្ឋានបានកំណត់)
  - គ. វិញ្ញាបនបត្រជំនាញរបស់អ្នកគ្រប់គ្រង ឬលិខិតបញ្ជាក់ជំនាញលក្ខណៈបច្ចេកទេសកីឡាដែលទទួលស្គាល់ដោយសហព័ន្ធកីឡាជាតិតាមប្រភេទកីឡានីមួយៗ ឬស្ថាប័នពាក់ព័ន្ធ (ក្នុងករណីចាំបាច់)
  - ឃ. កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម
  - ង. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស)
  - ច. រូបថតបច្ចុប្បន្នភាពរបស់អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ (៤X៦) ចំនួន ០៣សន្លឹក

**២.ចំពោះអាជីវកម្មកីឡាទេសចរណ៍៖** បាល់ឡុងបង្ហោះ រថយន្តខ្សែកាប យន្តហោះ ឬឧទ្ធម្ភាគចក្រជិះកម្សាន្ត។

- **ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ (ថ្មី) ត្រូវបំពេញសំណុំបែបបទ និងលក្ខខណ្ឌដូចខាងក្រោម៖**
  - ក. វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
  - ខ. លិខិតអនុញ្ញាតទីតាំងអាជីវកម្ម (ប្រកបអាជីវកម្មក្នុងទីតាំងដែលអាជ្ញាធរមូលដ្ឋានបានកំណត់)
  - គ. លិខិតបញ្ជាក់ពីអាជ្ញាធរអាកាសចរស៊ីវិល
  - ឃ. កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម
  - ង. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស)
  - ច. រូបថតបច្ចុប្បន្នភាពរបស់អ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ (៤X៦) ចំនួន ០៣សន្លឹក

**ប្រការ១១ ._**

បុគ្គលដែលស្នើសុំបន្តអាជីវកម្មកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានីខេត្ត ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធអនឡាញទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. អាជ្ញាបណ្ណទេសចរណ៍ (ថតចម្លង)

ខ. កិច្ចសន្យារបស់ប្រត្តិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម

គ. រូបថតបច្ចុប្បន្នភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ទំហំ ៤ X ៦ (ចំនួន ៣សន្លឹក)។

**ប្រការ១២ ._**

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណកីឡាទេសចរណ៍ត្រូវបានកែសម្រួល និងបន្ថែមក្នុងករណី(ថ្មី បន្ត ឬបិទអាជីវកម្ម) ដូចខាងក្រោម៖

ក. ករណីមានការផ្ទេរសិទ្ធិឈរឈ្មោះ ឬប្តូរម្ចាស់អាជ្ញាបណ្ណទេសចរណ៍ អ្នកស្នើសុំអាជ្ញាបណ្ណកីឡាទេសចរណ៍ដែលជាអ្នកទទួលសិទ្ធិឈរឈ្មោះ
ឬម្ចាស់អាជ្ញាបណ្ណទេសចរណ៍នោះត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ១០ និងប្រការ១១ ដូចខាងក្រោម៖

១. លិខិតប្រគល់សិទ្ធិ

២. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកផ្ទេរសិទ្ធិ (ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ចាស់ដែលត្រូវប្តូរ) (ថតចម្លង)

៣. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ (ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ថ្មី) (ថតចម្លង)

៤. វិញ្ញាបនបត្រជំនាញរបស់អ្នកគ្រប់គ្រង ឬផ្ទាំំដែលទទួលស្គាល់ដោយសហព័ន្ធកីឡានានា ឬស្ថាប័នពាក់ព័ន្ធ(ថតចម្លង) ក្នុងករណីចាំបាច់។

ខ. ករណីប្តូរនាមករណ៍ អ្នកស្នើសុំអាជ្ញាបណ្ណកីឡាទេសចរណ៍ ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ១០ និងប្រការ១១ដូចខាងក្រោម៖

១. លិខិតអនុញ្ញាតឱ្យប្តូរនាមករណ៍ថ្មីចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត

២. កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ទទួលខុសត្រូវចំពោះនាមករណ៍ចាស់។

**ប្រការ១៣ ._**

ក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិនឹងជូនដំណឹងទៅអ្នកស្នើសុំអំពីសេចក្តីសម្រេចឯកភាពផ្តល់ឱ្យ ឬមិនផ្តល់ឱ្យក្នុងរយៈពេល២៨ (ម្ភៃប្រាំបី)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកស្នើសុំបានបំពេញសំណុំបែបបទត្រឹមត្រូវតាមលក្ខណវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ១៤ ._**

អាជ្ញាបណ្ណទេសចរណ៍មានសុពលភាពអប្បបរមារយៈពេល០១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍ដោយក្រសួងទេសចរណ៍។

**ប្រការ១៥ ._**

ប្រសិនបើអ្នកស្នើសុំបានបំពេញបែបបទឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ និងការតម្រូវនានាដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងចេញអាជ្ញាបណ្ណទេសចរណ៍ជូនអ្នកស្នើសុំមានសុពលភាពរយៈពេល០១ឆ្នាំ (មួយឆ្នាំ)។ ក្នុងករណីអ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពុំអាចបំពេញបែបបទឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវនានាដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញអាជ្ញាបណ្ណបណ្ដោះអាសន្នដែលមានសុពលភាពក្រោយពេលអ្នកស្នើសុំបានបង់កម្រៃអាជ្ញាបណ្ណទេសចរណ៍រួច ដោយតម្រូវឱ្យអ្នកស្នើសុំធ្វើកិច្ចសន្យាបំពេញបន្ថែមនូវលក្ខខណ្ឌដែលមិនពេញលេញជាលាយលក្ខណ៍អក្សរ។

ក្នុងរយៈពេលកំណត់នៃកិច្ចសន្យា បើម្ចាស់អាជ្ញាបណ្ណទេសចរណ៍បណ្ដោះអាសន្នបានបំពេញតាមលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងផ្ដល់អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិដល់អ្នកស្នើសុំ។

ផ្ទុយទៅវិញក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញតាមលក្ខណវិនិច្ឆ័យនៃប្រកាសនេះ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា អាជ្ញាបណ្ណបណ្ដោះអាសន្នដែលចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអស់សុពលភាពនឹងត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ១៦ ._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ត្រូវដាក់ពាក្យសុំបន្តអាជ្ញាបណ្ណទេសចរណ៍ឱ្យបាន ៣០ថ្ងៃយ៉ាងតិច (សាមសិប) មុនថ្ងៃផុតកំណត់នៃសុពលភាពអាជ្ញាបណ្ណទេសចរណ៍ចាស់។

ក្នុងករណីដែលម្ចាស់អាជ្ញាបណ្ណទេសចរណ៍នៅតែបន្តអាជីវកម្មលើអាជ្ញាបណ្ណទេសចរណ៍ដែលអស់សុពលភាពនឹងត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ១៧. _**

ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍របស់ខ្លួនជាបណ្ដោះអាសន្នបានក្នុងរយៈពេល០១ឆ្នាំ ការស្នើសុំនេះមិនត្រូវលើសពី០២(ពីរ)ដង ដោយមានការយល់ព្រមពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៥

## លក្ខខណ្ឌនៃការប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍របស់ប្រតិបត្តិករទេសចរណ៍

**ប្រការ១៨. _**

ម្ចាស់អាជ្ញាបណ្ណកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

ក. ត្រូវប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍ឱ្យបានត្រឹមត្រូវ ស្របតាមកម្មវត្ថុនៃអាជីវកម្មរបស់ខ្លួន និងត្រូវគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តព្រមទាំងអនុវត្តតាមការណែនាំនានារបស់ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។

ខ. មិនត្រូវបានអនុញ្ញាតឱ្យបុគ្គល ឬម្ចាស់អាជីវកម្មកីឡាទេសចរណ៍ដទៃ ប្រើប្រាស់នាមករណ៍អាជ្ញាបណ្ណរបស់ខ្លួនឡើយ។

គ. មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការឈរឈ្មោះតំណាងឱ្យអាជីវកម្មកីឡាទេសចរណ៍ដទៃក្រៅពីអាជីវកម្មរបស់ខ្លួនឡើយ។

ឃ. ត្រូវដាក់តាំងអាជ្ញាបណ្ណទេសចរណ៍នៅកន្លែងទទួលភ្ញៀវដែលងាយមើលឃើញច្បាស់។

ង. ក្នុងករណីមានការខូចខាត ឬបាត់បង់អាជ្ញាបណ្ណទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ទុតិយតាក្នុងរយៈពេល ៣០ថ្ងៃ (សាមសិប) គិតពីថ្ងៃដែលខូចខាត ឬបាត់បង់។

## ជំពូកទី ៦
## ភារកិច្ចរបស់ប្រតិបត្តិករទេសចរណ៍

**ប្រការ១៩ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវអនុវត្តតាមកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៤៨ នៃច្បាប់ស្តីពីទេសចរណ៍ កាតព្វកិច្ចដែលកំណត់ក្នុងអនុក្រឹត្យលេខ៣៧អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈកីឡាទេសចរណ៍ដែលរៀបចំដោយក្រសួងទេសចរណ៍ ឬគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ឬសហព័ន្ធកីឡាជាតិតាមប្រភេទកីឡានីមួយៗ ឱ្យបានល្អ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២០ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវមានផែនការ និងមានសកម្មភាពបណ្តុះបណ្តាល និងហ្វឹកហ្វឺនដល់បុគ្គលិកបម្រើការងារអំពីជំនាញបដិសណ្ឋារកិច្ច ឬការគ្រប់គ្រងលក្ខណៈបច្ចេកទេសកីឡាស្របតាមការណែនាំរបស់ក្រសួងទេសចរណ៍ ឬសហព័ន្ធកីឡាជាតិតាមប្រភេទកីឡានីមួយៗ។

**ប្រការ២១ ._**

ប្រតិបត្តិករទេសចរណ៍ត្រូវផ្តល់របាយការណ៍ និងស្ថិតិពីអាជីវកម្មរបស់ខ្លួនជូនក្រសួងទេសចរណ៍តាមការស្នើសុំរបស់ក្រសួងទេសចរណ៍។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**ប្រការ២២ ._**

អាជីវកម្មកីឡាទេសចរណ៍គ្រប់ប្រភេទ គ្រប់ទម្រង់ ដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមខ្លឹមសារដែលមានចែងក្នុងប្រការ១៩ នៃប្រកាសនេះនឹងត្រូវទទួលទោសប្បញ្ញត្តិដែលមានចែងក្នុងជំពូកទី៦ នៃអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងការពិន័យអន្តរការណ៍ជាប្រាក់អនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងទេសចរណ៍។

**ប្រការ២៣ ._**

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍សម្រាប់អាជីវកម្មកីឡាទេសចរណ៍ ឬឯកសារសាធារណៈផ្សេងៗត្រូវផ្តន្ទាទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ២៤ ._**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២៥ ._**

អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្ត និងកីឡាទេសចរណ៍ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- រដ្ឋបាលរាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សហព័ន្ធកីឡាកម្ពុជា
- ដូចប្រការ២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ